# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៥៧...ស.ស.រ

## សេចក្តីសំរេច

ស្តីពី

## ការកែសំរួលសមាសភាពក្រុមការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់រដ្ឋធម្មនុញ្ញបន្ថែម សំដៅធានាទូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញសេចក្តីសំរេចលេខ ៣៤ ស.ស.រ ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការបង្កើតក្រុមការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រ
- បានឃើញសេចក្តីសំរេចលេខ ៤២ ស.ស.រ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីរបៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល
- តាមការចាំបាច់ចំពោះមុខរបស់រាជរដ្ឋាភិបាល

### សំរេច

**ប្រការ១ .-**

ត្រូវបានកែសំរួលសមាសភាព ក្រុមការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រ ដែលមានចែងក្នុងប្រការ១ នៃសេចក្តីសំរេចលេខ ៣៤ ស.ស.រ ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការបង្កើតក្រុម

ការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រ ដូចតទៅ :

| | | |
|---|---|---|
| ១-ឯកឧត្តម វេង សិរីវុឌ្ឍ | ទេសរដ្ឋមន្ត្រី | ប្រធាន |
| ២-ឯកឧត្តម ឡាយ ប្រហស្ត | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | អនុប្រធាន |
| ៣-ឯកឧត្តម ថោង ខុន | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធានប្រចាំការ |
| ៤-ឯកឧត្តម សួស គង់ | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | អនុប្រធាន |
| ៥- ឯកឧត្តម សុន គន្ធរ | អគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៦-ឯកឧត្តម ជុច ភឿន | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៧-ឯកឧត្តម ឡុង វិសាលោ | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការ អន្តរជាតិ | សមាជិក |
| ៨-ឯកឧត្តម ម៉ុន សម | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៩-ឯកឧត្តម ខៀវ មុត | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១០-ឯកឧត្តម នុត ណារ៉ាង | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១១-ឯកឧត្តម តេង ឡៅ | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១២-ឯកឧត្តម វេង សាខុន | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១៣-ឯកឧត្តម ញ៉ឹក ច្រឹង | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១៤-ឯកឧត្តម អ៊ឹង ភិរុន | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១៥-ឯកឧត្តម ភឹម ស៊ីថន | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៦-ឯកឧត្តម ថាច់ ជែន | រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ១៧-ឯកឧត្តម សារ៉ាក់ ខាន់ | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៨-ឯកឧត្តម ខឹម ពិសិដ្ឋ | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៩-ឯកឧត្តម អ៊ុក សារមេត្ត | អគ្គនាយករងអាជ្ញាធរអប្សរា | សមាជិក |
| ២០-ឯកឧត្តម សូ ម៉ារ៉ា | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | ប្រធានក្រុមលេខាធិការ និងជាសមាជិក |
| ២១-លោក ញឹម ខេមរា | ជំនួយការឯកឧត្តមទេសរដ្ឋមន្ត្រី វេង សិរីវុឌ្ឍ | លេខាធិការ |

**ប្រការ២ ..**

ក្រុមការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីសំរួលការងារ ។

**ប្រការ៣ ..**

លេខាធិការដ្ឋាន នៃក្រុមការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រ មានទីតាំងនៅទីស្តីការ-គណៈរដ្ឋមន្ត្រី ។

**ប្រការ៤ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៥ ..**

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន និងអភិបាលខេត្ត-ក្រុង ពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ដូចប្រការ៥
- ឯកសារ-កាលប្បវត្តិ